Reading Book

ពិភពរឿងនិទាន

The World of Stories

រឿង ក្មេងពេទ្យ ទេវតា

Godlike Doctor



M.56

គោលបំណង

រឿង **"គ្រូពេទ្យទេវតា"** មានបំណងអប់រំដល់ប្អូនៗ កុមារកុំឱ្យមានចិត្តលោភលន់ ។ ជាពិសេសជាងនេះទៅទៀតជួយអប់រំដល់អ្នកដែលតែងតែប្រើប្រាស់ថ្នាំពេទ្យឱ្យបានដឹងថា ការប្រើប្រាស់ថ្នាំហួសកំណត់ នឹងធ្វើឱ្យប៉ះពាល់ដល់សុខភាព ។ ដូចនេះ អ្នកគួរស្តាប់បង្គាប់នូវរាល់ពាក្យណែនាំរបស់គ្រូពេទ្យ ។

AIM

Godlike Doctor is aimed to educate children not to be a greedy person. It is moreover intended to educate medicine users to understand that overdose could harm their health. So, it is recommended that you follow every instruction of your doctor.





នៅក្នុងភូមិដ៏ចម្លែកមួយមានស្ត្រីមេម៉ាយកូនមួយ ឈ្មោះមីង **កន្តាំង**។ កូនរបស់គាត់ឈ្មោះអា **សង្វិត** មានអាយុ៣ឆ្នាំ។ កូននោះក៏ចម្លែកទៅទៀត គេមានមាឌតូចល្អិតជាងកូនអ្នកដទៃ។ រាល់ថ្ងៃគេញ៉ាំអាហារតិចណាស់។ មីង **កន្តាំង** ខ្មាសគេជាខ្លាំង ព្រោះកូនរបស់គាត់រូបរាងខុសគេ។ តែទោះជាយ៉ាងណាក៏ដោយក៏មីង **កន្តាំង** នៅតែស្រឡាញ់កូនរបស់គាត់ដែរ។

There lived a widow named Kantaing with a small son in a strange village. Her son was called Sangvit (thin) and aged 3 years old. Her son was also strange because he was so small in size compared to others. He ate very little. Auntie Kantaing felt shameful that her son looked weird to others. Auntie Kantaing, however, loved her son.





ពេលមីង **កន្ទាំង** ទៅណាម្តងៗគាត់តែង
នាំកូនប្រុសរបស់គាត់ទៅជាមួយ។ នៅ
តាមផ្លូវ អ្នកណាៗក៏ចង់មើលកូននេះ
ដែរ។


Everywhere she went, she had always brought her son along. On the ways, everyone wanted to see him.






ថ្ងៃមួយមីង **កន្តាំង** បាននាំកូនតូចរបស់
គាត់សំដៅទៅផ្ទះលោកគ្រូពេទ្យម្នាក់
នៅក្នុងភូមិនោះ ដែលអ្នកស្រុកតែងតែ
និយមហៅគាត់ថា **គ្រូពេទ្យទេវតា**។

One day, Auntie Kantaing brought her son to meet a doctor in the village, whom local people named Godlike doctor.



គ្រូពេទ្យទេវតា ជាគ្រូពេទ្យម្នាក់ដែលព្យាបាលតែជម្ងឺណាដែលប្លែកពីគេ។ គាត់ពិនិត្យមើលអា **សង្វិត** រួចក៏ប្រាប់ម្តាយឱ្យយកកូនត្រឡប់ទៅផ្ទះវិញជាមួយនឹងដបទទេមួយ។ គ្រូពេទ្យបានប្រាប់ទៅមីង **កន្តាំង** ថា "ពេលទៅដល់ផ្ទះ មីងយកដបនេះទៅច្រកទឹកឆ្អិនចាក់ឱ្យកូនផឹកទៅ នោះកូនមីងនឹងធំធាត់ដូចកូនអ្នកដទៃទៀតជាក់ជាមិនខាន"។

Godlike doctor was someone who treated only bizarre diseases. He examined Sangvit and told her mother to return home with an empty bottle. The doctor told Auntie Kantaing, "Arriving at your home, please fill in this bottle with boiled water and let you son drink it, then your son would grow and become fleshy like other children."





មីង **កន្តាំង** សប្បាយចិត្តណាស់។ គ្រាន់តែគាត់មកដល់ផ្ទះភ្លាម គាត់ក៏រៀបចំដាំទឹកឱ្យពុះ ហើយទុកទឹកនោះឱ្យត្រជាក់ ទើបច្រកបញ្ចូលក្នុងដប រួចចាក់ទឹកឱ្យកូនគាត់ផឹក។ អា **សង្វិត** ផឹកទឹកនោះហើយក៏ធំធាត់បន្តិចម្តងៗ។ វាចាប់ផ្តើមចេះឃ្លានអាហារ។ មីង **កន្តាំង** បានឱ្យទឹកដោះគោមួយកំប៉ុងទៅឱ្យកូនផឹក។ អា **សង្វិត** ផឹកទឹកដោះគោនោះទាល់តែអស់ពីកំប៉ុង។


Auntie Kantaing felt very happy. Arriving at her home, she immediately boiled water and kept it cool before pouring it into the bottle and got her son drink it. Sangvit drank the water, and he grew and got fleshier little by little. He started to have appetite. Auntie Kantaing gave him a can of milk. Sangvit drank the milk up to the end.





មីង **កន្តាំង** គិតថា កូនរបស់គាត់មិនទាន់ធំល្មម
នោះទេ គាត់ក៏ច្រកទឹកចូលទៅក្នុងដបនោះ
ឱ្យអា **សង្វិត** ផឹកទៀត។ បន្ទាប់មកកូនគាត់
កាន់តែធំទៅៗ។ គេក៏ចាប់ផ្តើមយំរកអាហារ
បន្ថែមទៀត "ឃ្លានណាស់..."។ មីង **កន្តាំង**
ក៏ទៅដាំបបរមួយឆ្នាំងធំឱ្យកូនគាត់ហូប។អា**សង្វិត**
ក៏ហូបបបរនោះអស់ទៀត។


Auntie Kantaing felt that her son had not grown and become fleshy enough, so she filled the bottle with more water for Sangvit. Her son grew more and more. He started to cry for more food, "I'm hungry...!" Auntie Kantaing made a large pot of porridge for her son. Sangvit ate all the porridge.





មីង **កន្តាំង**នៅតែគិតថា កូនរបស់គាត់មិនទាន់ធំសមនឹងចិត្តគាត់ទេ។ ដូច្នេះគាត់ក៏យកដបនោះទៅច្រកទឹកមកឱ្យកូនរបស់គាត់ផឹកទៀត។ អា **សង្វិត** ក៏ផឹកទឹកនោះទាល់តែអស់រលីង។ បន្ទាប់មកវាកាន់តែធំឡើងៗមិនឈប់សោះ។


Auntie Kantaing still thought that her son had not grown enough as what she wished. So, she further filled the bottle with boiled water for her son. Sangvit drank all the water. Then he grew incessantly.





ពេលនោះផ្ទះមីង **កន្តាំង** មិនអាចទប់ទល់នឹងទម្ងន់អា **សង្វិត** បានទេ។ បន្ទាប់មកផ្ទះរបស់គាត់ក៏បាក់គ្រាំង។ អា **សង្វិត**កាន់តែធំទៅៗ។ មីង **កន្តាំង** ស្រែកឡើង "បានហើយៗកូនឈប់ធំទៀតទៅ"។ តែអំណាចទឹកក្នុងដបនោះនៅតែធ្វើឱ្យកូនរបស់គាត់កាន់តែធំទៅៗមិនឈប់សោះ វាចេះតែស្រែក "ខ្ញុំឃ្លានណាស់ៗ..."។

At that time, Auntie Kantaing could no longer deal with Sangvit's weight. Her house collapsed.Sangvit grew more and more. Auntie Kantaing screamed,"It is enough, you should not grow any more." With the power of the water, her son kept growing endlessly, and he kept shouting, "I'm hungry...!"





មីង **កន្តាំង** ក៏ទៅដាំបាយមួយឆ្នាំង
យ៉ាងធំ និងម្ហូបមួយខ្ទះមកឱ្យកូនគាត់
តែគេហូបមិនឆ្អែតសោះ។ អា **សង្វិត**
ស្រែកយំកាន់តែខ្លាំងទៅៗធ្វើឱ្យអ្នក
ភូមិផ្អើលមកមើលត្រៀបត្រា។ មីង
កន្តាំង រវល់តែធ្វើអាហារឱ្យកូនរហូត
អស់អង្ករ។

Auntie Kantaing cooked a large pot of rice and a pan of fried food, yet it was not enough. Sangvit cried so loudly that villagers flocked to see him. Auntie Kantaing was busy with cooking rice for her son till her rice was empty.



មីងទ្រាំមិនបានក៏រត់ទៅរក**គ្រូពេទ្យទេវតា**។ ពេលគ្រូពេទ្យឃើញអា**សង្វិត** ធំខ្លាំងដូច្នេះ គាត់ក៏ប្រើវេទមន្តរបស់គាត់ "តូចភ្លាមអាកូនសម្លាញ់ ពេលកូនតូច កូនគួរឱ្យស្រឡាញ់ណាស់"។ ពេលនោះអា**សង្វិត**ក៏តូចបន្តិចម្តងៗរហូតមីង **កន្ត្រាំង** ស្រែកថា "លួមហើយៗ"។ អា**សង្វិត** ក៏មានមាឌដូចកូនគេដទៃទៀតនៅក្នុងភូមិនោះ។

គ្រូពេទ្យនិយាយទៅកាន់មីង **កន្តាំង** ថា "វេទមន្តនេះក៏ដូចជាថ្នាំពេទ្យដែរ ប្រសិនបើអ្នកប្រើប្រាស់វាហួសកំណត់នោះ អ្នកនឹងទទួលគ្រោះថ្នាក់ជាមិនខានឡើយ។ **ចប់**

មនតិសោធន៍ គឺជាមាតានៃបំណេះជីវ

She could no longer endure with such situation, and ran to meet the Godlike doctor. Seeing how fat Sangvit was, the doctor used his magic, saying that, "Become thinner now! When you are thinner, you would look lovely." Sangvit then was become smaller little by little to a size Auntie Kantaing said, "That's enough." Sangvit's size was that like other children in the village. The doctor said to Antie Kantaing, "The magic was also the same like medicines. Overdose could lead to harms."

Experience is the mother of wisdom

សំណួរ

១-តើកូនរបស់មីងកន្តាំងមានរូបរាងបែបណា?

២-លោកគ្រូពេទ្យទេវតាបានឱ្យអ្វីទៅមីងកន្តាំង?

៣-តើអាសង្ឃឹតមានរូបរាងបែបណា?

៤-តើមីងកន្តាំងមានអាហារគ្រប់សម្រាប់អាសង្ឃឹតដែរឬទេ?

៥-តើចុងក្រោយអាសង្ឃឹតមានរូបរាងបែបណា?

Questions

1- How did Auntie Kantaing's son look like?

2- What did the Godlike doctor give to Auntie Kantaing?

3- How did Sangvit look like?

4- Did Auntie Kantaing have enough food for Sangvit?

5- How did Sangvit look like at last?